scorocs®

Prove and improve the good you do.™

# ឧបករណ៍ប័ណ្ណដាក់ពិន្ទុភាពក្រីក្រលក្ខណៈសាមញ្ញ ប្រទេសកម្ពុជា

Mark Schreiner

ថ្ងៃទី ១០ ខែកញ្ញាឆ្នាំ ២០២១

This document and a data-collection tool are in English at scorocs.com
ឯកសារនេះ និងឧបករណ៍ប្រមូលទិន្នន័យ ជាភាសាខ្មែរមាននៅគេហទំព័រ scorocs.com

ឧបករណ៍វាយតម្លៃភាពក្រីក្រនៃប័ណ្ណដាក់ពិន្ទុភាពក្រីក្រលក្ខណៈសាមញ្ញឈ្មោះ Scorocs (the Scorocs® Simple Poverty Scorecard® poverty-assessment tool) គឺជាមធ្យោបាយដ៏មានតម្លាភាពនិងតម្លៃទាប សម្រាប់កម្មវិធីគាំទ្រដល់ជនក្រីក្រនៅក្នុងប្រទេសកម្ពុជា ដើម្បីស្វែងយល់អំពីអ្នកចូលរួមឱ្យបានកាន់តែប្រសើរជាងមុន ក្នុងគោលបំណងបង្ហាញនិងលើកកម្ពស់ការប្រព្រឹត្តិនៅក្នុងសង្គមរបស់ពួកគេ៖
ការឆ្លើយតបទៅនឹងសំណួរទាំង ១០ របស់ប័ណ្ណដាក់ពិន្ទុនេះអាចយកទៅប្រើដើម្បី៖

— ពិនិត្យមើលអត្រានៃភាពក្រីក្រ និងចំនួនប្រជាជនក្រីក្រក្នុងចំណោមអ្នកដែលមកចូលរួម
— តាមដានការផ្លាស់ប្តូរនៃភាពក្រីក្រក្នុងចំណោមអ្នកដែលកំពុងបន្តចូលរួម
— បែងចែកអ្នកចូលរួមជាផ្នែកដើម្បីការព្រឹត្តិផ្សេងៗពីគ្នាផ្អែកលើភាពក្រីក្រ

## កំណត់សម្គាល់អំពីកំណែឧបករណ៍

ប័ណ្ណដាក់ពិន្ទុថ្មីសម្រាប់ប្រទេសកម្ពុជាមួយនេះគឺផ្អែកទៅលើទិន្នន័យពីឆ្នាំ ២០១៧ ។ វាជំនួសឱ្យប័ណ្ណដាក់ពិន្ទុចាស់ក្នុង (២០០៩ និង ២០១៥) ផ្អែកលើទិន្នន័យមកពីឆ្នាំ ២០០៤ និង ២០១១ ។

## ការទទួលស្គាល់

ឯកសារនេះត្រូវបានផ្តល់មូលនិធិពី Private Sector Window របស់កម្មវិធី Global Agriculture and Food-Security Program និងដោយ International Finance Corporation ។ សូមថ្លែងអំណរគុណចំពោះ Yanni Chen, Sodeth Ly, Lundy Saint, និង Kimsun Tong។ ទិន្នន័យបានពីវិទ្យាស្ថានជាតិស្ថិតិរបស់ប្រទេសកម្ពុជា។ រដ្ឋាភិបាលនៃប្រទេសកម្ពុជាមិនបានបោះពុម្ពផ្សាយទូរលេខនៃភាពក្រីក្រដោយផ្អែកលើទិន្នន័យទាំងនេះទេ។ និយមន័យទិន្នន័យរបស់ *ភាពក្រីក្រ* មានភាពសាំញ៉ាំ ហើយកម្មវិធី PovcalNet (World Bank ក្នុងឆ្នាំ ២០១៧) មិនប្រើនិយមន័យនេះសម្រាប់ការប៉ានប្រមាណ "ភាពក្រីក្រខ្លាំង" របស់ខ្លួននោះទេ។ ឯកសារនេះត្រូវបានបកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរដោយ សាន់ តុលា ។

“Scorocs” and “Simple Poverty Scorecard” are Registered Trademarks (and “Prove and improve the good you do” and “PovIt!” are Trademarks) of Scorocs, L.L.C. for its brand of poverty-assessment tools. Copyright © 2021 Scorocs.

# Scorocs® Simple Poverty Scorecard® Tool

| | | | |
|---|---|---|---|
| អត្តសញ្ញាណនៃការសម្ភាស: | | ឈ្មោះ | លេខសម្គាល់ |
| កាលបរិច្ឆេទសម្ភាស: | | អ្នកចូលរួមក្នុងកំណត់ត្រា: | |
| ប្រទេស: | | ភ្នាក់ងារចុះដល់កន្លែង: | |
| ប័ណ្ណដាក់ពិន្ទុ: | 003 | ទីតាំងសេវាកម្ម: | |
| ចំនួនគំរូតំណាង: | | ចំនួនសមាជិកគ្រួសារ: | |

| សំណួរ | ចម្លើយ | ពិន្ទុ |
|---|---|---|
| ១. តើគ្រួសារនេះរស់នៅក្នុងខេត្តណា? | ក. ទីក្រុងភ្នំពេញ ឬ កោះកុង | 0 |
| | ខ. បាត់ដំបង តាកែវ សៀមរាប បន្ទាយមានជ័យ កំពង់ធំ ឧត្តមានជ័យ រតនគីរី ឬ ស្ទឹងត្រែង | 16 |
| | គ. កំពង់ចាម ត្បូងឃ្មុំ កណ្តាល ស្វាយរៀង កំពត កំពង់ឆ្នាំង ព្រះសីហនុ ព្រះវិហារ ឬ ក្រចេះ ឬ មណ្ឌលគីរី | 18 |
| | ឃ. ព្រៃវែង កំពង់ស្ពឺ ពោធិសាត់ កែប ឬ ប៉ៃលិន | 20 |
| ២. តើគ្រួសារនេះមានសមាជិកប៉ុន្មានអ្នកដែរ? | ក. ប្រាំបីនាក់ ឬច្រើនជាងនេះ | 0 |
| | ខ. ប្រាំពីរនាក់ | 3 |
| | គ. ប្រាំមួយនាក់ | 5 |
| | ឃ. ប្រាំនាក់ | 9 |
| | ង. បួននាក់ | 16 |
| | ច. បីនាក់ | 22 |
| | ឆ. មួយ ឬ ពីរនាក់ | 30 |
| ៣. តើលំនៅដ្ឋានដែលគ្រួសារប្រើដើម្បីរស់នៅមានប៉ុន្មានបន្ទប់ដែរ (ជាជាងផ្ទះបាយ បង្គន់ និង បន្ទប់ទឹក)? | ក. មួយបន្ទប់ | 0 |
| | ខ. ពីរបន្ទប់ | 2 |
| | គ. បីបន្ទប់ឬច្រើនជាងនេះ | 6 |
| ៤. តើបាតបន្ទប់ក្នុងលំនៅដ្ឋានដែលគ្រួសាររស់នៅធ្វើពីវត្ថុធាតុសំណង់អ្វីដែរភាគច្រើន? *(អង្កេតហើយកត់ត្រា)* | ក. ដី ដីឥដ្ឋ ឬ ផ្សេងទៀត | 0 |
| | ខ. បន្ទះឬស្សី ក្តារក្រាល/ឈើរលោង បន្ទះឈើ ឬ ស៊ីម៉ងត៍/ដុំឥដ្ឋ/ | 2 |
| | គ. ក្បឿងសេរ៉ាមិក ថ្មរលោង/ថ្មម៉ាប ឬ ប្លាស្ទិក | 7 |
| ៥. តើគ្រួសារមានឈុតតុសម្រាប់ពិសាអាហារដែរឬទេ (តុនិងកៅអីបាយ)? | ក. មិនមានទេ | 0 |
| | ខ. មាន | 2 |
| ៦. តើគ្រួសារនេះមានចង្ក្រានអគ្គិសនី ឬចង្ក្រានហ្គាសប៉ុន្មានដែរ? | ក. គ្មានទេ | 0 |
| | ខ. មានមួយ | 3 |
| | គ. មានពីរឬច្រើនជាងនេះ | 7 |
| ៧. តើគ្រួសារនេះមានម៉ូតូ (រួមទាំងម៉ូតូអគ្គិសនី) ឡាន ឬឡានវ៉ែន/ហ្វ៊ីបប៉ុន្មានគ្រឿងដែរ? | ខ. មានមួយ | 0 |
| | ខ. មានមួយ | 6 |
| | គ. មានពីរឬច្រើនជាងនេះ | 9 |
| ៨. តើគ្រួសារនេះមានទូរសព្ទដៃប្រើប៉ុន្មានគ្រឿងដែរ? | ខ. មានមួយ | 0 |
| | ខ. មានមួយ | 2 |
| | គ. មានពីរឬច្រើនជាងនេះ | 7 |
| ៩. តើមានប៉ុន្មានថ្ងៃដែរកាលពី ៧ ថ្ងៃកន្លងមកនេះ (ពោលគឺតាំងពី ថ្ងៃបច្ចុប្បន្ននៃសប្តាហ៍ មុនរហូតដល់ម្សិលមិញ) ដែលគ្រួសារនេះបានពិសាផ្លែចេក ផ្លែប៉ោម ផ្លែក្រូច ឬផ្លែក្រូចឃ្វិច? | ខ. មានមួយ | 0 |
| | ខ. មានមួយ | 6 |
| | គ. មានពីរឬច្រើនជាងនេះ | 9 |
| ១០. កាលពី ៧ ថ្ងៃកន្លងមកនេះ (ពោលគឺតាំងពី ថ្ងៃបច្ចុប្បន្ននៃសប្តាហ៍ មុនរហូតដល់ម្សិលមិញ) តើគ្រួសារនេះមានបរិភោគផលិតផលធ្វើពីទឹកដោះគោ (ទឹកដោះគោស្រស់ ទឹកដោះគោខាប់ ឬម្សៅទឹកដោះគោ ការ៉េមគី ឈីស ឬផលិតផលធ្វើពីទឹកដោះគោផ្សេងទៀត) ដែរឬទេ? | ក. មិនមានទេ | 0 |
| | ខ. មាន | 3 |


Copyright © 2021 Scorocs.
Score:

# សន្លឹកឯកសារទំព័រខាងខ្នង៖ ចំនួនសមាជិកគ្រួសារ

ចូរបំពេញផ្នែកខាងលើប័ណ្ណដាក់ពិន្ទុជាមុនសិន។ ចូររួមបញ្ចូលទាំងលេខសម្គាល់ដែលខុសពីគេរបស់ការសម្ភាស (បើដឹង) កាលបរិច្ឆេទនៃការសម្ភាស និងចំនួនគំរូតំណាងរបស់គ្រួសារដែលបានចូលរួម (បើដឹង)។ បន្ទាប់មក ចូរកត់ត្រាឈ្មោះពេញ និងលេខសម្គាល់ខុសពីគេរបស់អ្នកចូលរួមក្នុងកំណត់ត្រា (ជាអ្នកដែលអាចខុសពីអ្នកឆ្លើយ) លេខសម្គាល់របស់ភ្នាក់ងារចុះដល់កន្លែង ដែលបម្រើដល់អ្នកចូលរួមក្នុងកំណត់ត្រា (ជាអ្នកដែលអាចខុសពីអ្នកសម្ភាសផ្ទាល់) និងលេខសម្គាល់របស់ទីតាំងសេវាកម្មដែលអ្នកចូលរួមក្នុងកំណត់ត្រាបានប្រើ (បើមាន និងដឹង)។ គូសរង្វង់ជុំវិញចម្លើយរបស់សំណួរទីមួយក្នុងប័ណ្ណដាក់ពិន្ទុផ្អែកទៅតាមខេត្តដែលជាកន្លែងរបស់គ្រួសារអ្នកចូលរួមរស់នៅ។

បន្ទាប់មក អានឱ្យអ្នកឆ្លើយតបស្តាប់៖ *សូមប្រាប់ខ្ញុំអំពីឈ្មោះខ្លួន ឬឈ្មោះហៅក្រៅរបស់សមាជិកក្នុងគ្រួសារម្នាក់ៗ។ គ្រួសារមួយ គឺជាមនុស្សម្នាក់ ឬច្រើននាក់ដែលជាអ្នករស់នៅជាមួយគ្នា ហើយប្រើប្រាស់ឧបករណ៍រួមសម្រាប់ម្ហូបអាហារ ដូចជាការប្រើផ្ទះបាយរួម ឬការទិញម្ហូបដោយចំណាយប្រាក់រួម ដោយមិនគិតអំពីភាពជាប់សាច់ឈាមនឹងគ្នា។ សមាជិកក្នុងគ្រួសារមិនមានលំនៅដ្ឋានអចិន្ត្រៃយ៍ផ្សេងទៀត ហើយការស្នាក់នៅតាមការគ្រោងទុក ឬការស្នាក់នៅជាក់ស្តែងរបស់ពួកគេនៅក្នុងគ្រួសារមានរយៈពេលយ៉ាងហោចណាស់ ១២ ខែ។ កម្មករចំណាកស្រុក ឬកម្មករមកពីចម្ងាយ (ដូចជាកម្មកររោងចក្រកាត់ដេរ) ក៏ត្រូវរាប់បញ្ចូលផងដែរ ប្រសិនបើពួកគេទៅសួរសុខទុក្ខគ្រួសារយ៉ាងហោចណាស់ម្តងក្នុងមួយខែ។*

កត់ត្រាឈ្មោះខ្លួន ឬឈ្មោះហៅក្រៅរបស់សមាជិកគ្រួសារទាំងអស់ ដោយចាប់ផ្តើមពីមេគ្រួសារ និងប្តីឬប្រពន្ធ (ដែលមានវ័យចំណាស់ជាងគេ) របស់គាត់ (បើមានម្នាក់ ដែលជាសមាជិកនៅក្នុងគ្រួសារផងដែរនោះ)។ គូសចំណាំមេគ្រួសារ និងប្តីឬប្រពន្ធរបស់គាត់ (បើមាន)។ កត់ត្រាចំនួនសមាជិកក្នុងគ្រួសារនៅក្នុងក្បាលប័ណ្ណដាក់ពិន្ទុបន្ទាប់ពីពាក្យ "ចំនួនសមាជិកក្នុងគ្រួសារ៖" ។ បន្ទាប់មក គូសរង្វង់ជុំវិញចម្លើយរបស់សំណួរទីពីរ ក្នុងប័ណ្ណដាក់ពិន្ទុ អំពីចំនួនសមាជិកក្នុងគ្រួសារ។

អានសំណួរដែលនៅសល់ឱ្យឮ (លើកលែងតែសំណួរទីបួនអំពីវត្ថុធាតុចម្បងរបស់ផ្ទៃបាតបន្ទប់)។សម្រាប់សំណួរមួយនេះ ក្នុងនាមជាអ្នកសម្ភាស អ្នកគួរតែព្យាយាមអង្កេតនិងកត់ត្រាវត្ថុធាតុដើមចម្បងរបស់ផ្ទៃបាតបន្ទប់ ដោយមិនចាំបាច់សួរសំណួរដោយផ្ទាល់ទៅកាន់អ្នកឆ្លើយ។ ប្រសិនបើអ្នកមិនច្បាស់អំពីចម្លើយដែលសមរម្យ នោះសូមសួរសំណួរទៅអ្នកឆ្លើយ ហើយកត់ត្រាចម្លើយរបស់ពួកគេ។

ត្រូវចាំទុកក្នុងចិត្ត និងប្រើការណែនាំលម្អិតដែលមាននៅក្នុងផ្នែក ការណែនាំអំពីការសម្ភាស ជានិច្ច។

| ឈ្មោះខ្លួនឬឈ្មោះហៅក្រៅ? | មេគ្រួសារ ឬប្តីឬប្រពន្ធរបស់មេគ្រួសារ? |
|---|---|
| ១. | មេគ្រួសារ (ប្រុស)<br>មេគ្រួសារ (ស្រី) |
| ២. | ប្រពន្ធចាស់ជាងគេរបស់ប្តីជាមេគ្រួសារ<br>ប្តីរបស់ស្ត្រីជាមេគ្រួសារ<br>សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៣. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៤. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៥. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៦. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៧. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៨. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៩. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ១០. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ១១. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ១២. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ១៣. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| **ចំនួនសមាជិកគ្រួសារ៖** | — |

# ការណែនាំអំពីការសម្ភាស

អត្ថបទដកស្រង់នៅទីនេះបានមកពីៈ

វិទ្យាស្ថានជាតិស្ថិតិ(២០១២) “Field-Operations Manual for Interviewers and Supervisors: Cambodia Socio-Economic Survey 2012” [*កូនសៀវភៅណែនាំ*], តំណ។

និង

_____ (២០១៧) “Household Questionnaire: Cambodia Socio-Economic Survey 2017”, [*កម្រងសំណួរ*].

## 1. ការណែនាំអំពីការសម្ភាសជាមូលដ្ឋាន

អ្នកសម្ភាសអាចបំពេញប័ណ្ណដាក់ពិន្ទុពីក្រដាសនៅពេលចុះសម្ភាស ដោយបញ្ចូលចម្លើយនៅពេលក្រោយទៅក្នុងតារាងឯកសារ ឬនៅក្នុងឃ្លាំងទិន្នន័យផ្ទាល់របស់អ្នក។ ជាជម្រើស ឧបករណ៍ប្រមូលទិន្នន័យដែលផ្អែកលើប្រព័ន្ធអ៊ីនធឺណិតរបស់ Scorocs ដំណើរការជាមួយនឹងកម្មវិធីបើកគេហទំព័រ ឬកម្មវិធីនៅក្នុងទូរសព្ទប្រព័ន្ធ Android ដែលជាការផ្តល់លទ្ធភាពដល់ការបញ្ចូលទិន្នន័យបានពីកន្លែងចុះសម្ភាស ឬនៅក្នុងការិយាល័យ។ ប្រសិនបើមិនមានការតភ្ជាប់បណ្តាញទេនោះ ទិន្នន័យនឹងត្រូវបានរក្សាទុកនៅក្នុងឧបករណ៍រហូតទាល់តែមានបណ្តាញតភ្ជាប់។ **សាកសួរអំពីគណនីឯកជន**។

ប័ណ្ណដាក់ពិន្ទុនេះគួរតែប្រើប្រាស់ដោយអ្នកសម្ភាសដែលទទួលបានការបណ្តុះបណ្តាលក្នុងការអនុវត្តតាម **ការណែនាំអំពីការសម្ភាស** នេះ។

បំពេញក្បាលប័ណ្ណដាក់ពិន្ទុ និងផ្នែក សន្លឹកឯកសារទំព័រខាងខ្នង ជាមុនសិន បន្ទាប់មកធ្វើតាមការណែនាំនៅលើផ្នែក សន្លឹកឯកសារទំព័រខាងខ្នង"។

នៅក្នុងក្បាលប័ណ្ណដាក់ពិន្ទុ បំពេញចំនួនរបស់សមាជិកក្នុងគ្រួសារផ្អែកទៅលើបញ្ជីដែលអ្នកក្នុងនាមជាអ្នកសម្ភាស បានបង្កើតឡើងជាផ្នែកមួយរបស់ សន្លឹកឯកសារទំព័រខាងខ្នង ។

កុំសួរសំណួរទីមួយក្នុងប័ណ្ណដាក់ពិន្ទុ (“តើគ្រួសារនេះរស់នៅក្នុងខេត្តណា?”)"ដោយផ្ទាល់។ ផ្ទុយទៅវិញ បំពេញចម្លើយផ្អែកទៅលើការយល់ដឹងរបស់អ្នកអំពីខេត្តដែលគ្រួសាររស់នៅ។

តាមរបៀបដូចគ្នានេះ កុំសួរសំណួរទីពីរនៅក្នុងប័ណ្ណដាក់ពិន្ទុ (“តើគ្រួសារនេះមានសមាជិកប៉ុន្មានអ្នកដែរ?”)"ដោយផ្ទាល់។ ផ្ទុយទៅវិញ គួសចំណាំចម្លើយផ្អែកទៅលើចំនួននៃសមាជិកគ្រួសារដែលបានចុះបញ្ជីនៅលើឯកសារ សន្លឹកឯកសារទំព័រខាងខ្នង។

សួរសំណួរដែលនៅសល់ទាំងអស់ដោយផ្ទាល់ទៅកាន់អ្នកឆ្លើយតប លើកលែងតែសំណួរទីបួន (“តើបាតបន្ទប់ក្នុងលំនៅដ្ឋានដែលគ្រួសាររស់នៅធ្វើពីវត្ថុធាតុសំណង់អ្វីដែរភាគច្រើន?”)។ សម្រាប់សំណួរមួយនេះ ក្នុងនាមជាអ្នកសម្ភាស អ្នកគួរតែព្យាយាមអង្កេតនិងកត់ត្រាវត្ថុធាតុសំណង់ចម្បងរបស់ផ្ទៃបាតបន្ទប់ ដោយមិនចាំបាច់សួរសំណួរដោយផ្ទាល់ទៅកាន់អ្នកឆ្លើយ។"

ប្រសិនបើអ្នកមិនច្បាស់នៅក្នុងចិត្តអំពីចម្លើយដែលត្រឹមត្រូវ សូមសួរសំណួរនោះទៅអ្នកឆ្លើយ។

## ការណែនាំទូទៅអំពីការសម្ភាស

ចូរសិក្សាអំពី [ការណែនាំអំពីការសម្ភាស]

 នេះដោយយកចិត្តទុកដាក់ និងយកវាតាមខ្លួនពេលអ្នកធ្វើការ។ ធ្វើតាមការណែនាំនៅក្នុង [ការណែនាំអំពីការសម្ភាស]

 នេះ(រួមទាំងការណែនាំមួយនេះ)។

ចូរចងចាំថា អ្នកឆ្លើយនៅក្នុងការសម្ភាសនេះមិនចាំបាច់ជាសមាជិកគ្រួសារ ដែលជាអ្នកចូលរួមក្នុងកំណត់ត្រានៃកម្មវិធីរបស់អ្នកនោះទេ។

ដូចគ្នានេះផងដែរ ភ្នាក់ងារចុះដល់កន្លែងដែលត្រូវកត់ត្រាចូលក្នុងក្បាលប័ណ្ណដាក់ពិន្ទុមិនចាំបាច់ជាមនុស្សដូចគ្នាទៅនឹងអ្នកសម្ភាស ដែលចុះសម្ភាសនោះទេ។ ផ្ទុយទៅវិញ ភ្នាក់ងារចុះដល់កន្លែងគឺជាបុគ្គលិករបស់កម្មវិធីគាំទ្រជនក្រីក្រ ដែលអ្នកចូលរួមក្នុងកំណត់ត្រាមានទំនាក់ទំនងជាបន្តបន្ទាប់ជាមួយរូបគេ។ ប្រសិនបើមិនមានភ្នាក់ងារចុះដល់កន្លែងដូច្នេះទេនោះ ចូរសរសេរពាក្យថា “គ្មាន” ឬ “មិនដឹង”។

អានសំណួរនីមួយៗឱ្យឮគ្រប់ពាក្យ (លើកលែងតែមានការបញ្ជាក់ដូចខាងលើ) តាមលំដាប់លំដោយដែលមាននៅក្នុងប័ណ្ណដាក់ពិន្ទុ។

ពេលអ្នកគូសចម្លើយមួយនៅលើសំណួរក្នុងប័ណ្ណដាក់ពិន្ទុ ត្រូវសរសេរតម្លៃពិន្ទុនៅក្នុងក្រឡាន “Score” ហើយ បន្ទាប់មកគូសរង្វង់ជុំវិញជម្រើសចម្លើយដែលមានសរសេរ តម្លៃពិន្ទុដែលបានបោះពុម្ពទុកមុន និងពិន្ទុដោយការសរសេរដៃ ដូច្នេះ៖

| | | | |
|---|---|---|---|
| ៣. តើលំនៅដ្ឋានដែលគ្រួសារប្រើដើម្បីរស់ នៅមានប៉ុន្មានបន្ទប់ដែរ (ជាជាងផ្ទះបាយ បង្គន់ និងបន្ទប់ទឹក)? | ក. ដី ដីឥដ្ឋ ឬ ផ្សេងទៀត | 0 | |
| | ខ. បន្ទះឬស្សី ក្តារក្រាល/ឈើរលោង បន្ទះឈើ ឬ ស៊ីម៉ងត៍/ដុំឥដ្ឋ/ថ្ម | 2 | 2 |
| | គ. គ្រឿងសេរ៉ាមិក ថ្មរលោង/ថ្មម៉ាប ឬ ប្លាស្ទិក | 6 | |

ពេលបញ្ហាមួយកើតឡើង ដែលមិនបានលើកឡើងនៅក្នុង **ការណែនាំអំពីការសម្ភាស**

មួយនេះ គួរតែទុកឱ្យការវិនិច្ឆ័យរបស់អ្នកសម្ភាសនិងអ្នកឆ្លើយដោយមិនមានជំនួយជាអ្នកសម្រេចលើដំណោះស្រាយ ព្រោះថាជាក់ស្តែងនោះគឺជាការអនុវត្តរបស់វិទ្យាស្ថានជាតិស្ថិតិកម្ពុជាក្នុងការស្ទង់មតិសង្គម-សេដ្ឋកិច្ចនាឆ្នាំ ២០១៧។ ពោលគឺ កម្មវិធីមួយមិនគួរផ្សព្វផ្សាយនិយមន័យ ឬច្បាប់វិន័យណាមួយ (ក្រៅពីនិយមន័យនិងច្បាប់វិន័យដែលមាននៅក្នុង **ការណែនាំអំពីការសម្ភាស** នេះ) ដើម្បីឱ្យអ្នកសម្ភាសរបស់កម្មវិធីប្រើទាំងអស់គ្នានោះទេ។ អ្វីមួយដែលមិនមានលើកឡើងជាពិសេសនៅក្នុង **ការណែនាំអំពីការសម្ភាស**

នេះនឹងត្រូវទុកឱ្យការវិនិច្ឆ័យដោយមិនមានជំនួយរបស់អ្នកសម្ភាសនិងអ្នកឆ្លើយម្នាក់ៗជាអ្នកសម្រេច។

កុំអានជម្រើសក្នុងចម្លើយទៅកាន់អ្នកឆ្លើយ។ ផ្ទុយទៅវិញ អានសំណួរ និងបន្ទាប់មក ឈប់ដើម្បីរង់ចាំចម្លើយ។ ប្រសិនបើអ្នកឆ្លើយសួររកការបំភ្លឺ ឬមិនដូច្នោះទេ មានភាពស្ទាក់ស្ទើរ ឬហាក់ដូចជាច្រឡំ ចូរអានសំណួរម្តងទៀត ឬក៏ផ្តល់ជំនួយបន្ថែមផ្អែកលើ **ការណែនាំអំពីការសម្ភាស** នេះ ឬតាមដែលអ្នក ក្នុងនាមជាអ្នកសម្ភាស ចាត់ទុកថាសមរម្យ។

ជាទូទៅ អ្នកគួរទទួលយកចម្លើយ ដូចដែលផ្តល់ជូនដោយអ្នកឆ្លើយ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើអ្នកឆ្លើយនិយាយអ្វីមួយ ឬប្រសិនបើអ្នកមើលឃើញ ឬមានអារម្មណ៍ដឹងអ្វីមួយ ដែល

ប្រាប់អ្នកថាចម្លើយអាចនឹងមិនមានភាពត្រឹមត្រូវ ឬថាអ្នកឆ្លើយមិនប្រាកដក្នុងចិត្ត ឬថាអ្នកឆ្លើយមានបំណងចង់បានជំនួយដើម្បីស្វែងយល់ពីរបៀបឆ្លើយតប នោះអ្នកគួរតែអានសំណួរម្តងទៀត ហើយផ្តល់ជំនួយគ្រប់យ៉ាងដែលអ្នកចាត់ទុកថាសមស្របផ្អែកទៅលើ **ការណែនាំអំពីការសម្ភាស** នេះ។

ខណៈពេលដែលចម្លើយទៅនឹងសំណួរភាគច្រើននៅក្នុងប័ណ្ណដាក់ពិន្ទុនេះអាចផ្ទៀងផ្ទាត់បានក្នុងករណីភាគច្រើន អ្នកមិនចាំបាច់ធ្វើការផ្ទៀងផ្ទាត់ចម្លើយនោះទេ។ អ្នកគួរតែធ្វើការផ្ទៀងផ្ទាត់លុះត្រាតែអ្វីមួយធ្វើឱ្យអ្នកយល់ថា ចម្លើយមួយប្រហែលជាមិនត្រឹមត្រូវ ដូច្នេះហើយការផ្ទៀងផ្ទាត់ប្រហែលជាអាចកែលម្អគុណភាពទិន្នន័យ។ ឧទាហរណ៍៖ អ្នកប្រហែលជាជ្រើសរើសធ្វើការផ្ទៀងផ្ទាត់ ប្រសិនបើអ្នកឆ្លើយមានភាពស្ទាក់ស្ទើរ មើលទៅដូចជាមានការភ័យខ្លាច ឬបញ្ចេញសញ្ញាដែលថា គេអាចកំពុងតែនិយាយកុហក ច្រឡំ ឬមិនច្បាស់ក្នុងចិត្ត។ ដូចគ្នានេះដែរ ការផ្ទៀងផ្ទាត់ប្រហែលជាមានលក្ខណៈសមស្របប្រសិនបើកុមារម្នាក់នៅក្នុងគ្រួសារដែលគេសម្ភាស ឬប្រសិនបើអ្នកជិតខាងនិយាយអ្វីមួយដែលមិនស្របទៅតាមចម្លើយរបស់អ្នកឆ្លើយ។ ការផ្ទៀងផ្ទាត់ក៏ជាគំនិតដ៏ល្អផងដែរ ប្រសិនបើអ្នកអាចឃើញអ្វីមួយដោយខ្លួនអ្នកដែលអាចជាការបង្ហាញថា ចម្លើយប្រហែលជាមិនត្រឹមត្រូវ ដូចជាការឃើញផលិតផលដែលប្រើបានយូរដែល អ្នកឆ្លើយបានអះអាងថាមិនមានជាកម្មសិទ្ធិ ឬកុមារកំពុងតែញ៉ាំចំណីអាហារក្នុងបន្ទប់ តែមិនបានរាប់បញ្ចូលថាជាសមាជិកនៅក្នុងគ្រួសារ។

ជាទូទៅ ការអនុវត្តប្រើប័ណ្ណដាក់ពិន្ទុគួរតែមានលក្ខណៈស្រដៀងគ្នាខ្លាំងតាមដែលអាចធ្វើទៅបាន ទៅនឹងការអនុវត្តការស្ទង់មតិសង្គម-សេដ្ឋកិច្ចឆ្នាំ ២០១៧ ដោយវិទ្យាស្ថានជាតិស្ថិតិកម្ពុជា។ ឧទាហរណ៍៖ ការសម្ភាសគួរតែធ្វើឡើងដោយផ្ទាល់ដោយអ្នកសម្ភាសដែលមានការបណ្តុះបណ្តាលនៅឯលំនៅឋានរបស់អ្នកចូលរួមក្នុងកំណត់ត្រា ព្រោះថានោះគឺជាអ្វីដែលវិទ្យាស្ថានជាតិស្ថិតិបានធ្វើនៅក្នុងការស្ទង់មតិសង្គម-សេដ្ឋកិច្ចនាឆ្នាំ ២០១៧។

### ការបកប្រែ

ស្របតាមសំណេរជាលាយលក្ខណ៍អក្សរនេះ ប័ណ្ណដាក់ពិន្ទុផ្ទាល់ "សន្លឹកឯកសារទំព័រខាងខ្នង" និង ការណែនាំអំពីការសម្ភាស

នេះមានតែជាភាសាអង់គ្លេសនិងភាសាខ្មែរប៉ុណ្ណោះ។ ពុំទាន់មានការបកប្រែជាផ្លូវការប្រកបដោយវិជ្ជាជីវៈទៅជាភាសាដទៃទៀត ដែលគេនិយាយនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ អ្នកប្រើគួរតែពិនិត្យនៅ scorocs.com ដើម្បីមើលថាតើមានការបកប្រែអ្វីខ្លះ ដែលបានធ្វើឡើងចាប់តាំងពីសំណេរមួយនេះ ។

ប្រសិនបើមិនទាន់មានការបកប្រែជាផ្លូវការប្រកបដោយវិជ្ជាជីវៈទៅកាន់ភាសាដែលខ្លួនចង់បានទេនោះ សូមទាក់ទងមកកាន់ Scorocs ដើម្បីសហការធ្វើការបកប្រែភាសាមួយនោះ។

## 2. ការណែនាំទូទៅអំពីការសម្ភាសពី *សៀវភៅណែនាំ*

### តើអ្នកណាគួរតែជាអ្នកឆ្លើយ?

ចូរចងចាំថា អ្នកឆ្លើយមិនចាំបាច់ជាសមាជិកគ្រួសារ ដែលជាអ្នកចូលរួមក្នុងកំណត់ត្រានៃកម្មវិធីរបស់អ្នកនោះទេ (ទោះបីជា អ្នកឆ្លើយអាចជាអ្នកចូលរួមក្នុងកំណត់ត្រាក៏ដោយ)។

យោងតាមទំព័រទី 1 នៃ*កម្រងសំណួរ* "គេគួរតែសួរសំណួរទៅកាន់មេគ្រួសារ ប្តីឬប្រពន្ធរបស់មេគ្រួសារ ឬប្រសិនបើទាំងមេគ្រួសារ និងប្តីឬប្រពន្ធរបស់មេគ្រួសារមិនមានវត្តមាន ត្រូវសួរសមាជិកជាមនុស្សពេញវ័យម្នាក់ទៀតនៅក្នុងគ្រួសារ"។

យោងតាមទំព័រទី 8 នៃ *សៀវភៅណែនាំ* "[អ្នក] អាចសម្ភាសសមាជិកដែលមានទំនួលខុសត្រូវណាម្នាក់នៅក្នុងគ្រួសារ ជាអ្នកដែលអាចផ្តល់ចម្លើយយ៉ាងត្រឹមត្រូវដល់សំណួរ និងអាចផ្តល់ព័ត៌មានសម្រាប់គ្រួសារនោះ។ មេគ្រួសារ និង/ឬប្តីឬប្រពន្ធរបស់គេគឺជាជនដែលមានលក្ខណៈសម្បត្តិសមស្របបំផុតក្នុងការឆ្លើយតប។"

យោងតាមទំព័រទី 24 នៃ *សៀវភៅណែនាំ* ប័ណ្ណដាក់ពិន្ទុ "គួរតែយកទៅប្រើជាមួយមេគ្រួសារ រឺប្តីឬប្រពន្ធរបស់មេគ្រួសារ។ ប្រសិនបើមិនអាចប្រើកម្រងសំណួរដើម្បីសួរទៅកាន់មនុស្សណាម្នាក់នៃបុគ្គលទាំងនេះទេ (ឧទាហរណ៍៖ ពីព្រោះពួកគេទាំងពីរមិនមានវត្តមាន) នោះគេអាចប្រើកម្រងសំណួរជាមួយមនុស្សពេញវ័យម្នាក់ទៀតដែលជាសមាជិកនៅក្នុងគ្រួសារ ដែលមានចំណេះដឹងគ្រប់គ្រាន់។"

## តើអ្នកណាជាមេគ្រួសារ?

ចូរកត់សម្គាល់ថា មេគ្រួសារអាចជា ឬអាចមិនមែនជាសមាជិកគ្រួសារ ដែលជាអ្នកចូលរួមក្នុងកំណត់ត្រាជាមួយនឹងកម្មវិធី (បើទោះបីជាមេគ្រួសារអាចជាអ្នកចូលរួមក្នុងកំណត់ត្រាក៏ដោយ)។

## របៀបធ្វើសម្ភាសៈ

យោងតាមទំព័រទី 8 និងទី 9 នៃ *សៀវភៅណែនាំ* "ការទទួលបានព័ត៌មានពេញលេញ និងត្រឹមត្រូវគឺជាគោលបំណងចម្បង. . . . ក្នុងនាមជាអ្នកសម្ភាស អ្នកត្រូវតែមានភាពរាបសារគ្រប់ពេលវេលា។ ស្របពេលជាមួយគ្នានេះ ត្រូវធ្វើខ្លួនជាជនដែលមានសិទ្ធិអំណាចល្មមគ្រប់គ្រាន់ ដើម្បីទទួលបានជំនឿចិត្ត និងការជឿជាក់របស់អ្នកឆ្លើយ។

"ជោគជ័យនៃការធ្វើសម្ភាសអាស្រ័យទៅលើការបង្កើតចំណាប់អារម្មណ៍ដ៏ល្អរបស់អ្នក។ ចូរធ្វើតាមការណែនាំទាំងនេះ៖

*"ត្រូវមានរូបរាងសមរម្យ។* ធ្វើឱ្យមានចំណាប់អារម្មណ៍ល្អៗដោយការស្លៀកពាក់បានសមរម្យ និងស្អាតបាត។ មនុស្សមួយចំនួនវាយតម្លៃអ្នកផ្សេងទៀតតាមរយៈអ្វីដែលពួកគេស្លៀកពាក់ ហើយអាចនឹងមិនបើកទ្វារទទួលស្វាគមន៍អ្នកណាម្នាក់ដែលមើលទៅរញ៉េរញ៉ៃ ឬគ្មានសណ្តាប់ធ្នាប់នោះទេ។

"*ចូរណែនាំអំពីខ្លួនអ្នក និងអំពីការស្ទង់មតិ។* ខណៈដែលអ្នកមិនអាចគ្រប់គ្រងរបៀបដែលអ្នកដទៃនឹងមានប្រតិកម្មចំពោះអ្នកក៏ដោយ ខ្លួនអ្នកផ្ទាល់អាចមានភាពរួសរាយរាក់ទាក់ និងភាពរាបសារបានជានិច្ច។ ព្យាយាមញញឹមជានិច្ច។ ត្រៀមខ្លួនសម្រាប់សំណួរគ្រប់ប្រភេទ ហើយផ្តល់ចម្លើយដែលស្មោះត្រង់។ កុំឈ្លោះឬប្រកែកជាមួយនឹងអ្នកឆ្លើយ។ រក្សាភាពស្ងៀមស្ងាត់របស់អ្នក សូម្បីតែពេលអ្នកឆ្លើយហាក់ដូចជាមានចិត្តខឹង ឬព្រងើយកណ្តើយក៏ដោយ។

*"ត្រូវមានភាពរាបសារ។* ការណែនាំខ្លួនជាការចាំបាច់។ ដើម្បីធ្វើការណែនាំខ្លួន ចូរនិយាយថា៖ " សួស្តី/ជំរាបសួរ ខ្ញុំឈ្មោះ [ឈ្មោះរបស់អ្នក] ជាអ្នកសម្ភាសមកពីកម្មវិធី [កម្មវិធីរបស់អ្នក]។ នេះជាប័ណ្ណសម្គាល់ខ្លួនរបស់ខ្ញុំ។ បច្ចុប្បន្ននេះ ខ្ញុំ [កំពុងតែប្រមូលទិន្នន័យពីគ្រួសារជាអ្នកចូលរួមក្នុងកម្មវិធីរបស់យើងមួយចំនួន ដើម្បីស្វែងយល់ពីរបៀបរស់នៅរបស់ពួកគេ]។ ខ្ញុំពិតជាអរគុណចំពោះការឆ្លើយតបរបស់អ្នកទៅនឹងសំណួររបស់យើង។ ខ្ញុំសូមធានាថា ចម្លើយទាំងអស់នឹងត្រូវរក្សាជាការសម្ងាត់បំផុត។'

*"ពន្យល់ពីគោលបំណងនៃការស្ទង់មតិ។* ធ្វើដូច្នេះបើចាំបាច់ ដើម្បីទទួលបានការសហការ។

*"ចូរអាន និងអនុវត្តតាមការណែនាំនៅ ["សន្លឹកឯកសារទំព័រខាងខ្នង"] យ៉ាងប្រុងប្រយ័ត្ន។* ផ្ទុំខ្លួននឹង [ប័ណ្ណដាក់ពិន្ទុ]។

*"សួរគ្រប់សំណួរទាំងអស់។* កុំស្មានចម្លើយឱ្យសោះ [លើកលែងតែពេលដែល **[ការណែនាំអំពីការសម្ភាស]**

និយាយយ៉ាងច្បាស់ផ្សេងពីនេះ]។ សួរសំណួរសូម្បីតែពេលអ្នកគិតថាអ្នកដឹងចម្លើយរួចហើយក៏ដោយ។ ការស្មានរបស់អ្នកអាចនឹងមិនត្រឹមត្រូវ។ [ជាករណីលើកលែង សូម *កុំ* សួរសំណួរទីបួន("តើបាតបន្ទប់ក្នុងលំនៅដ្ឋានដែលគ្រួសាររស់នៅធ្វើពីវត្ថុធាតុសំណង់អ្វីដែរភាគច្រើន?")។ ផ្ទុយទៅវិញ ក្នុងនាមជាអ្នកសម្ភាស អ្នកគួរតែព្យាយាមអង្កេតនិងកត់ត្រាវត្ថុធាតុសំណង់ចម្បងរបស់បាតបន្ទប់ ដោយមិនចាំបាច់សួរសំណួរដោយផ្ទាល់ទៅកាន់អ្នកឆ្លើយ។ ប្រសិនបើអ្នកមិនច្បាស់នៅក្នុងចិត្តអំពីចម្លើយដែលត្រឹមត្រូវ សូមសួរសំណួរនោះទៅអ្នកឆ្លើយ។]

"ប្រសិនបើអ្នកមិនយល់សំណួរឬនីតិវិធីណាមួយ ដំបូងត្រូវពិគ្រោះជាមួយ [**ការណែនាំអំពីការសម្ភាស** នេះ]។ [ប្រសិនបើ**ការណែនាំអំពីការសម្ភាស**

មិនមានដំណោះស្រាយសម្រាប់បញ្ហាទេនោះ សូមប្រើសុភវិនិច្ឆ័យរបស់អ្នក។]

*"អង្កេតប្រសិនបើចម្លើយណាមួយមិនទាន់ពេញលេញតាមការពេញចិត្ត។* កុំទទួលយកចម្លើយដែលមិនពេញលេញតាមការពេញចិត្ត។ ផ្ទុយទៅវិញ ចូរអង្កេតដើម្បីស្វែងរកព័ត៌មានបន្ថែម។ អ្នកក៏អាច៖

- សួរសំណួរម្តងទៀត។ ការសួរសំណួរជាថ្មីអាចនឹងជួយអ្នកឆ្លើយឱ្យនឹកឃើញឡើងវិញ
- ពន្យល់ពីគោលគំនិត។ អ្នកប្រហែលជាត្រូវពន្យល់ពាក្យពិបាកៗ ឬពាក្យបច្ចេកទេសមួយចំនួនជាពាក្យសាមញ្ញ។

*"អរគុណអ្នកឆ្លើយសម្រាប់ការសហការរបស់គេ។* បន្សល់ទុកអារម្មណ៍ល្អៗដល់អ្នកឆ្លើយតបអំពីការស្ទង់មតិនេះ។ សម្តែងចេញអំណរគុណរបស់អ្នកសម្រាប់ការសហការរបស់គេ។ ឧទាហរណ៍៖ និយាយពាក្យថា "អរគុណច្រើនសម្រាប់ពេលវេលាឆ្លើយសំណួរ។"

*"បន្ទាប់ពីការសម្ភាសនីមួយៗ ចូរពិនិត្យ [ប័ណ្ណដាក់ពិន្ទុ] ឡើងវិញដើម្បីរកមើលកន្លែងលុបដែលអាចមាន។* ប្រសិនបើមានអ្វីមួយដែលបាត់ សូមធ្វើការកែតម្រូវជាមួយនឹងជំនួយពីអ្នកឆ្លើយ។"

## របៀបសួរសំណួរ

យោងតាមទំព័រទី 9 និងទី 10 នៃ *សៀវភៅណែនាំ* "ធ្វើតាមវិធានទាំងនេះ ពេលសួរសំណួរ៖

"*សួរគ្រប់សំណួរទាំងអស់ឱ្យដូចនឹងពាក្យដែលមានក្នុង [ប័ណ្ណដាក់ពិន្ទុ]។* [ជាករណីលើកលែង *កុំ* អានសំណួរទីមួយទៅកាន់អ្នកឆ្លើយ ("តើគ្រួសារនេះរស់នៅក្នុងខេត្តណា?") ផ្ទុយទៅវិញ បំពេញចម្លើយផ្អែកលើចំណេះដឹងរបស់អ្នកអំពីខេត្ត ដែលគ្រួសាររស់នៅ។] ការផ្លាស់ប្តូរពាក្យអាចប្តូរអត្ថន័យរបស់សំណួរ ហើយទីបំផុត នឹងប្តូរចម្លើយ។ សំណួរត្រូវបានសរសេរឡើងយ៉ាងយកចិត្តទុកដាក់ដើម្បី [ផ្គូផ្គងឱ្យដូចរបៀបដែលគេសួរសំណួរក្នុងការស្ទង់មតិសង្គម-សេដ្ឋកិច្ច]. . . . អ្នកមិនគួរបកស្រាយសំណួរ ឬព្យាយាមធ្វើឱ្យវាកាន់តែច្បាស់លាស់ ឬងាយយល់នោះទេ។ ប្រសិនបើអ្នកឆ្លើយសុំឱ្យបំភ្លឺ វាជាការប្រសើរក្នុងការផ្តល់ព័ត៌មានបន្ថែម ប៉ុន្តែលុះត្រាតែចំនុចនោះមាននៅក្នុង [**ការណែនាំអំពីការសម្ភាស**

នេះ"] ប្រសិនបើអ្នកឆ្លើយនៅតែមិនអាចផ្តល់ចម្លើយបាន [នោះ ចូរប្រើសុភវិនិច្ឆ័យរបស់អ្នកក្នុងការសម្រេចគូសយកជម្រើសនៃការឆ្លើយតបដែលល្អបំផុត។]។

"*ចូរសួរសំណួរតាមលំដាប់លំដោយដែលមាននៅក្នុង [ប័ណ្ណដាក់ពិន្ទុ]។* កុំរំលងចំណុចណាមួយ។ ជាករណីលើកលែង *កុំ* អានសំណួរទីមួយទៅកាន់អ្នកឆ្លើយ ("តើគ្រួសារនេះរស់នៅក្នុងខេត្តណា?") ផ្ទុយទៅវិញ បំពេញចម្លើយផ្អែកលើចំណេះដឹងរបស់អ្នកអំពីខេត្ត ដែលគ្រួសាររស់នៅ។ សម្រាប់សំណួរទីពីរ ("តើគ្រួសារនេះមានសមាជិកប៉ុន្មានអ្នកដែរ?")ដំបូងបំពេញសន្លឹកឯកសារទំព័រខាងខ្នង បន្ទាប់មកគូសរង្វង់ជុំវិញជម្រើសចម្លើយដែលសមស្រប ផ្អែកលើអ្វីដែលបានកត់ត្រានៅក្នុងសន្លឹកឯកសារទំព័រខាងខ្នង។]

"*កុំអានជម្រើសក្នុងចម្លើយទៅកាន់អ្នកឆ្លើយ។* ព្យាយាមស្វែងរកជម្រើសចម្លើយ ដែលសក្តិសមនឹងចម្លើយរបស់អ្នកឆ្លើយបំផុត។ ប្រសិនបើមិនមានជម្រើសសក្តិសមទេនោះ ចូរគូសយកជម្រើសចម្លើយ ដែលរួមមានពាក្យ "ផ្សេងទៀត" [ប្រសិនបើមានជម្រើសចម្លើយមួយនេះ]។ ការស្ទង់មតិនេះត្រូវបានរចនាឡើងដើម្បីទទួលយកព័ត៌មានពីអ្នកឆ្លើយ មិនមែនដើម្បីផ្តល់ព័ត៌មានដល់អ្នកឆ្លើយនោះទេ។ ចូរស្តាប់ប្រកបដោយជំនាញដើម្បីធានាថា ការស្ទង់មិតនេះទទួលបានព័ត៌មានត្រឹមត្រូវពីអ្នកឆ្លើយ។ ក្នុងករណីលើកលែងមួយចំនួន ដែលក្នុងនោះអ្នកឆ្លើយហាក់ដូចជាមិនអាចយល់បានថាត្រូវឆ្លើយតបវិញបែបណា អ្នកអាចលើកឡើងជម្រើសនៃចម្លើយមួយចំនួនបានដើម្បីផ្តល់គំនិតខ្លះៗដល់គេ។ ប៉ុន្តែ ចំណុចនេះជាករណីលើកលែងទៅនឹងវិធានសម្ភាស។

"*ផ្ទៀងផ្ទាត់ថាបានកត់ត្រាចម្លើយសម្រាប់ចំណុចទាំងអស់។*

*"កុំសួរសំណួរដឹកនាំឱ្យសោះ។ សំណួរដឹកនាំ*ជាសំណួរដែលដឹកនាំទៅចម្លើយដែលអ្នករំពឹងថាមាន។ ដោយការសួរសំណួរដឹកនាំ អ្នកបានរៀបឱ្យអ្នកឆ្លើយជឿជាក់ថាចម្លើយដែលសំណួរដឹកនាំទៅរកនោះគឺជាចម្លើយដ៏ត្រឹមត្រូវមួយ។ ឧទាហរណ៍នៃសំណួរដឹកនាំមានដូចជា៖ ‘តើអ្នកជាមេគ្រួសារនេះមែនដែរឬទេ?’ វិធីសួរដែលល្អជាងនេះគឺ៖ "តើអ្នកណាទៅជាមេគ្រួសារក្នុងគ្រួសារនេះ?" ឧទាហរណ៍មួយទៀតគឺ៖ "តើអ្នកប្រើអស់អង្ករ ១០ គីឡូមែនទេកាលពីសប្តាហ៍មុន? [ផ្ទុយទៅនឹងការសួរបែបអព្យាក្រឹត្យថា "តើអ្នកប្រើអស់អង្ករច្រើនប៉ុនណាកាលពីសប្តាហ៍មុន?"]

*“ត្រូវមានភាពអព្យាក្រឹត្យជាដាច់ខាត។* មនុស្សភាគច្រើនមានភាពសុភាពរាបសារពីធម្មជាតិជាពិសេសជាមួយភ្ញៀវ ហើយពួកគេទំនងនឹងព្យាយាមធ្វើឱ្យភ្ញៀវសប្បាយចិត្ត។ កុំបង្ហាញអារម្មណ៍ភ្ញាក់ផ្អើល ការយល់ព្រម ឬ ការយល់ទាស់ណាមួយអំពីចម្លើយរបស់អ្នកឆ្លើយ។ ប្រសិនបើអ្នកឆ្លើយសុំមតិយោបល់របស់អ្នក កុំប្រាប់គេអំពីអ្វីដែលអ្នកគិតចំពោះប្រធានបទនោះដោយខ្លួនឯង។ ផ្ទុយទៅវិញ ចូរពន្យល់ថាការស្ទង់មតិនេះព្យាយាមចង់ស្វែងយល់អំពីអ្វីដែលអ្នកឆ្លើយគិតឃើញ។ កុំពិភាក្សាអំពីមតិផ្ទាល់របស់អ្នកជាមួយនឹងអ្នកឆ្លើយ រហូតទាល់តែពេលបន្ទាប់ពីការសម្ភាសបានបញ្ចប់។ ចូរចងចាំថា បើទោះបីជាអ្នកជាអ្នកទទួលខុសត្រូវលើការសម្ភាសនេះក្តី ហើយថាបើទោះបីជាអ្នកត្រូវតែជាអ្នកគ្រប់គ្រងស្ថានការគ្រប់ពេលវេលាក៏ដោយ អ្នកក៏មានវត្តមាននៅទីនោះដើម្បីស្តាប់នូវអ្វីដែលអ្នកឆ្លើយត្រូវនិយាយជាការឆ្លើយតបទៅនឹងសំណួរដែលចោទសួរ។ តែងតែព្យាយាមធ្វើខ្លួនជាអ្នកស្តាប់ប្រកបដោយជំនាញជានិច្ច ហើយជៀសវាងកុំព្យាយាមជ្រៀតជ្រែក ឬបង្វែរទិសដៅចម្លើយទៅកាន់ចម្លើយណាមួយជាក់លាក់។

*“រក្សាចង្វាក់នៃការសម្ភាសឱ្យបានល្អ។* ជៀសវាងកុំពិភាក្សាអំពីសំណួរយូរពេក។ ប្រសិនបើអ្នកទទួលបានចម្លើយដែលសាំញ៉ាំ ឬមិនទាក់ទងនឹងសំណួរ កុំបង្អាក់ចម្លើយភ្លាមៗពេក។ ចូរស្តាប់ដោយយកចិត្តទុកដាក់ចំពោះអ្វីដែលអ្នកឆ្លើយនិយាយ ហើយបន្ទាប់មកដឹកនាំគេឱ្យត្រលប់មកកាន់សំណួរដើមវិញ។

“បញ្ចប់ការកត់ត្រាចម្លើយមុនពេលបន្តទៅកាន់សំណួរបន្ទាប់។”

## តើត្រូវធ្វើអ្វីពេលអ្នកឆ្លើយមានការលំបាកក្នុងការឆ្លើយតប៖

យោងតាមទំព័រទី 13 នៃ *សៀវភៅណែនាំ* "មានសំណួរមួយចំនួនដែលអ្នកឆ្លើយខ្លះនឹងមិនអាចឆ្លើយរួច។ នេះអាចដោយសារតែពួកគេមិន៖

- ចងចាំបានល្អ
- គិតគូរឃើញព័ត៌មាន
- យល់សំណួរ

# 3. គោលការណ៍ណែនាំសម្រាប់សំណួរនីមួយៗក្នុងប័ណ្ណដាក់ពិន្ទុ

### ១. តើគ្រួសារនេះរស់នៅក្នុងខេត្តណា?

ក. ទីក្រុងភ្នំពេញ ឬ កោះកុង
ខ. បាត់ដំបង តាកែវ សៀមរាប បន្ទាយមានជ័យ កំពង់ធំ ឧត្តមានជ័យ រតនគីរី ឬ ស្ទឹងត្រែង
គ. កំពង់ចាម ត្បូងឃ្មុំ កណ្តាល ស្វាយរៀង កំពត កំពង់ឆ្នាំង ព្រះសីហនុ ព្រះវិហារ ឬ ក្រចេះ ឬ មណ្ឌលគីរី
ឃ. ព្រៃវែង កំពង់ស្ពឺ ពោធិសាត់ កែប ឬ ប៉ៃលិន

កុំសួរសំណួរទីមួយក្នុងប័ណ្ណដាក់ពិន្ទុ ដោយផ្ទាល់។ ផ្ទុយទៅវិញ បំពេញចម្លើយផ្អែកទៅលើការយល់ដឹងរបស់អ្នកអំពីខេត្តដែលគ្រួសាររស់នៅ។

## ២. តើគ្រួសារនេះមានសមាជិកប៉ុន្មានអ្នកដែរ?

ក. ប្រាំបីនាក់ ឬច្រើនជាងនេះ
ខ. ប្រាំពីរនាក់
គ. ប្រាំមួយនាក់
ឃ. ប្រាំនាក់
ង. បួននាក់
ច. បីនាក់
ឆ. មួយ ឬ ពីរនាក់

តាមរបៀបដូចគ្នានេះ កុំសួរសំណួរទីពីរនៅក្នុងប័ណ្ណដាក់ពិន្ទុ"ដោយផ្ទាល់។ ផ្ទុយទៅវិញ គូសចំណាំចម្លើយផ្អែកទៅលើចំនួននៃសមាជិកគ្រួសារដែលបានចុះបញ្ជីនៅលើឯកសារ សន្លឹកឯកសារទំព័រខាងខ្នង។

យោងតាមទំព័រទី 26 នៃ *សៀវភៅណែនាំ* គ្រួសារមួយគឺជា "ក្រុមមនុស្ស (ឬមនុស្សតែម្នាក់) ដែលរស់នៅជាមួយគ្នា ហើយដែលរៀបចំម្ហូបអាហាររួមគ្នា ដូចជាការប្រើចង្ក្រានបាយរួម ឬ មានថវិកាទិញម្ហូបរួមគ្នា។ មនុស្សទាំងនេះអាចនឹងមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ឬអាចមិនមែនជាសាច់ញាតិ ដោយរាប់បញ្ចូលទាំង អ្នកនៅបម្រើ ឬបុគ្គលិកផ្សេងទៀត ដែលស្នាក់នៅជាមួយនិយោជក។

"សិស្ស អ្នកមកស្នាក់នៅជាមួយ និងបុគ្គលិក ដែលរស់នៅក្នុងលំនៅស្ថានរបស់គ្រួសារ និងដែលមានការរៀបចំចំណីអាហាររួមជាមួយនឹងគ្រួសារ ត្រូវចាត់ទុកថាជា *សមាជិករបស់គ្រួសារ* ប្រសិនបើពួកគេបានរស់នៅក្នុងគ្រួសារនោះលើសពីរយៈពេលមួយឆ្នាំ ឬប្រសិនបើពួកគេមិនមានកន្លែងស្នាក់នៅដទៃ។

"យ៉ាងណាក្តី ប្រសិនបើមានអ្នកមកស្នាក់នៅជាមួយ/អ្នកស្នាក់អាស្រ័យប្រាំនាក់ ឬច្រើនជាងនេះក្នុងផ្ទៃកមួយនៃលំនៅដ្ឋាន នោះពួកគេមិនគួរត្រូវបានរាយការណ៍ថាជា *សមាជិករបស់គ្រួសារ* ដែលពួកគេបង់ប្រាក់បន្ទប់និងចំណីអាហារទៅឱ្យនោះទេ។"

យោងតាមទំព័រទី 27 "នៃ *សៀវភៅណែនាំ សមាជិកគ្រួសារមួយ* គឺជាបុគ្គលណាម្នាក់ដែលបានរស់នៅជាធម្មតាក្នុងលំនៅដ្ឋានរបស់គ្រួសារដែលត្រូវបានសម្ភាស ហើយដែលមានការរៀបចំម្ហូបអាហាររួមគ្នាអស់រយៈពេលយ៉ាងហោចណាស់មួយឆ្នាំ ឬអ្នកដែលមិនមានលំនៅដ្ឋានដទៃទៀត។

“ដូច្នេះហើយ សិស្សភាគច្រើនដែលទៅសិក្សានៅសាលាឆ្ងាយពីផ្ទះត្រូវបានចាត់ទុកថាជា *សមាជិកគ្រួសាររបស់ពួកគេ* ជាជាងសមាជិកគ្រួសារ [ដែលនៅជិត] សាលារបស់ពួកគេ លុះត្រាតែពួកគេបានស្នាក់នៅជាបន្តបន្ទាប់ជាមួយគ្រួសារដែលនៅជិតសាលារបស់ពួកគេនោះរយៈពេលយូរជាងមួយឆ្នាំ។

“បុគ្គលដែលបានផ្លាស់ទីលំនៅថ្មីៗ (ពោលគឺ តិចជាងមួយឆ្នាំ) ត្រូវបានចាត់ទុកថាជា *សមាជិករបស់គ្រួសារ* នៅគោលដៅរស់នៅរបស់គេ ប្រសិនបើគេមិនមានគម្រោងត្រលប់មកកាន់គ្រួសារពីមុនវិញក្នុងរយៈពេលមួយឆ្នាំទេនោះ។ ស្រដៀងគ្នានេះដែរ បុគ្គលដែលបានផ្លាស់ទីលំនៅចេញពីគ្រួសារមួយថ្មីៗ ដោយមិនមានបំណងត្រលប់មកវិញទេនោះ គឺលែងត្រូវបានចាត់ទុកថាជា *សមាជិកក្នុងគ្រួសារ* នោះទៀតហើយ។

“បុគ្គលម្នាក់ត្រូវបានរាប់ថាជា *សមាជិកគ្រួសារ* ប្រសិនបើគេរស់នៅទីនោះ ឬអវត្តមានតិចជាងរយៈពេល ១២ ខែ។

“បុគ្គលដែលបានចាកចេញពីគ្រួសារដែលត្រូវបានសម្ភាសយូរជាងរយៈពេលមួយឆ្នាំ និងនៅតែមកលេងគ្រួសារដែលត្រូវបានសម្ភាសត្រឹមតែម្តងម្កាល (ដូចជាសម្រាប់តែពេលថ្ងៃបុណ្យជាតិសំខាន់ៗ ដែលមានពីរបីដងក្នុងមួយឆ្នាំ) មិនត្រូវបានចាត់ទុកថាជា *សមាជិករបស់គ្រួសារ*ដែលបានសម្ភាសនោះទេ។ ទោះជាយ៉ាងណា បុគ្គលដែលមានលំនៅដ្ឋានដាច់ដោយឡែកអស់រយៈពេលយូរជាងមួយឆ្នាំ ប៉ុន្តែមកលេងផ្ទះទៀងទាត់ (ជាធម្យម ម្តងក្នុងមួយខែ ឬញឹកញាប់ជាងនេះទៀត) នៅតែត្រូវចាត់ទុកថាជា *សមាជិករបស់គ្រួសារដែលត្រូវបានសម្ភាស* (ឧទាហរណ៍ កម្មកររោងចក្រកាត់ដេរ) ។

“ប្តីប្រពន្ធទើបរៀបការណ៍ថ្មីថ្មោង (ឧទាហរណ៍ ៖ កូនប្រសារប្រុស ឬ កូនប្រសារស្រី) ដែលទើបតែបានចូលរួមក្នុងគ្រួសារ កុមារទើបកើត ឬសមាជិកគ្រួសារដែលធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀតដើម្បីធ្វើការ ឬជាអ្នកដែលត្រលប់មកផ្ទះវិញយ៉ាងទៀងទាត់ពីកន្លែងធ្វើការ (សម្រាប់ចុងសប្តាហ៍ ឬពេលខ្លះ នៅចុងខែ ដូចជាកម្មកររោងចក្រកាត់ដេរ) ត្រូវបានចាត់ទុកថាជា *សមាជិករបស់គ្រួសារដែលបានសម្ភាស*។

“អ្នកទើបរៀការថ្មីថ្មោង ដែលបានផ្លាស់លំនៅចេញពីគ្រួសារដែលត្រូវបានសម្ភាស មនុស្សដែលបានស្លាប់ ជាដើម មិនត្រូវរាប់បញ្ចូលជា *សមាជិកធម្មតានៃគ្រួសារនោះទេ។”*

**៣. តើលំនៅដ្ឋានដែលគ្រួសារប្រើដើម្បីរស់នៅមានប៉ុន្មានបន្ទប់ដែរ (ជាជាងផ្ទះបាយ បង្គន់ និង បន្ទប់ទឹក)?**

ក. មួយបន្ទប់
ខ. ពីរបន្ទប់
គ. បីបន្ទប់ឬច្រើនជាងនេះ

យោងតាមទំព័រទី 35 នៃ *សៀវភៅណែនាំ* “សួររកចំនួនបន្ទប់ក្នុងលំនៅដ្ឋាន ដែលគ្រួសារដែលត្រូវបានសម្ភាសនោះប្រើ។ បន្ទប់មួយត្រូវតែមានជញ្ជាំងបួន ដំបូល និងទ្វារចេញ។ វាត្រូវតែធំល្មម និងវែងល្មមសម្រាប់មនុស្សម្នាក់ដេកខាងក្នុងបាន។ ពេលរាប់ចំនួនបន្ទប់ដែលប្រើប្រាស់ដោយគ្រួសារដែលត្រូវបានសម្ភាស អ្នកគួរតែដកផ្ទះបាយ បន្ទប់ដាក់អីវ៉ាន់ បន្ទប់ទឹក និងបង្គន់ចេញ ព្រោះថាបន្ទប់ទាំងនេះជាទូទៅមិនត្រូវបានប្រើសម្រាប់ការរស់នៅ ឬដេកនោះទេ។ បន្ទប់មួយដែលប្រើរួមដោយគ្រួសារច្រើនជាងមួយ មិនត្រូវរាប់ថា បានកាន់កាប់ដោយគ្រួសារដែលបានប្រើរួមណាមួយនោះឡើយ។”

### ៩. តើបាតបន្ទប់ក្នុងលំនៅដ្ឋានដែលគ្រួសាររស់នៅធ្វើពីវត្ថុធាតុសំណង់អ្វីដែរភាគច្រើន?

ក. ដី ដីឥដ្ឋ ឬ ផ្សេងទៀត
ខ. បន្ទះឬស្សី ក្ដារក្រាល/ឈើរលោង បន្ទះឈើ ឬ ស៊ីម៉ង់ត៍/ដុំឥដ្ឋ/ថ្ម
គ. ក្បឿងសេរ៉ាមិក ថ្មរលោង/ថ្មម៉ាប ឬ ប្លាស្ទិក

យោងតាមទំព័រទី 35 នៃ *សៀវភៅណែនាំ* សំណួរនេះអាចឆ្លើយបានតាមរយៈការអង្កេត។ ប៉ុន្តែប្រសិនបើមានការសង្ស័យ នោះចូរសួរសំណួរទៅអ្នកឆ្លើយ។

"ប្រសិនបើផ្ទៃបាតលំនៅដ្ឋានរបស់គ្រួសារដែលត្រូវបានសម្ភាស ធ្វើពីវត្ថុធាតុច្រើនជាងមួយប្រភេទ នោះ [កត់ត្រាប្រភេទវត្ថុធាតុដែលជាចំណែកផ្ទៃបាតលំនៅដ្ឋានច្រើនជាងគេ] ។"

### ៥. តើគ្រួសារមានឈុតតុសម្រាប់ពិសាអាហារដែរឬទេ (តុនិងកៅអីបាយ)?

ក. មិនមានទេ

ខ. មាន

យោងតាមវិទ្យាស្ថានជាតិស្ថិតិ ឈុតតុសម្រាប់ពិសាអាហារដែលបាក់បែកប៉ុន្តែអាចជួសជុលបាន គួរតែត្រូវរាប់បញ្ចូលសម្រាប់គោលបំណងនៃសំណួរនេះ។ ឈុតតុពិសាអាហារដែលខ្ចីពីគេមិនគួររាប់បញ្ចូលនោះទេ។

*កូនសៀវភៅណែនាំ* មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

### ៦. តើគ្រួសារនេះមានចង្ក្រានអគ្គិសនី ឬចង្ក្រានហ្គាសប៉ុន្មានដែរ?

ក. មួយបន្ទប់
ខ. ពីរបន្ទប់
គ. បីបន្ទប់ឬច្រើនជាងនេះ

យោងតាមវិទ្យាស្ថានជាតិស្ថិតិ ចង្ក្រានអគ្គិសនី ឬចង្ក្រានហ្គាសដែលខូចប៉ុន្តែអាចជួសជុលបាន គួរតែត្រូវរាប់បញ្ចូលសម្រាប់គោលបំណងនៃសំណួរនេះ។ ចង្ក្រានអគ្គិសនី ឬចង្ក្រានហ្គាសដែលខ្ញីគេមិនគួររាប់បញ្ចូលនោះទេ។

*កូនសៀវភៅណែនាំ* មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

**៧. តើគ្រួសារនេះមានម៉ូតូ (រួមទាំងម៉ូតូអគ្គិសនី) ឡាន ឬឡានវ៉ែន/ហ្ស៊ីបប៉ុន្មានគ្រឿងដែរ?**

ក. មួយបន្ទប់
ខ. ពីរបន្ទប់
គ. បីបន្ទប់ឬច្រើនជាងនេះ

យោងតាមវិទ្យាស្ថានជាតិស្ថិតិ ម៉ូតូ (រួមទាំងម៉ូតូអគ្គិសនី) ឡាន និងឡានហ្ស៊ីប/ឡានវ៉ែន ដែលខូចតែអាចជួសជុលបាន គួរតែត្រូវបានរាប់បញ្ចូលសម្រាប់គោលបំណងនៃសំណួរមួយនេះ។ ម៉ូតូ (រួមទាំងម៉ូតូអគ្គិសនី) ឡាន និងឡានហ្ស៊ីប/ឡានវ៉ែន ដែលខ្ទីគេមិនគួររាប់បញ្ចូលនោះទេ។ *កូនសៀវភៅណែនាំ* មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

### ៨. តើគ្រួសារនេះមានទូរសព្ទដៃប្រើប៉ុន្មានគ្រឿងដែរ?

ក. មួយបន្ទប់
ខ. ពីរបន្ទប់
គ. បីបន្ទប់ឬច្រើនជាងនេះ

យោងតាមវិទ្យាស្ថានជាតិស្ថិតិ ទូរសព្ទដៃដែលខូចប៉ុន្តែអាចជួសជុលបាន គួរតែត្រូវរាប់បញ្ចូលសម្រាប់គោលបំណងនៃសំណួរនេះ។ ទូរសព្ទដៃដែលខ្ចីពីគេមិនគួររាប់បញ្ចូលនោះទេ។

*កូនសៀវភៅណែនាំ* មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

**៩. តើមានប៉ុន្មានថ្ងៃដែរកាលពី ៧ ថ្ងៃកន្លងមកនេះ (ពោលគឺតាំងពី ថ្ងៃបច្ចុប្បន្ននៃសប្ដាហ៍ មុនរហូតដល់ម្សិលមិញ) ដែលគ្រួសារនេះបានពិសាផ្លែចេក ផ្លែប៉ោម ផ្លែក្រូច ឬផ្លែក្រូចឃ្វិច?**

ក. មួយបន្ទប់
ខ. ពីរបន្ទប់
គ. បីបន្ទប់ឬច្រើនជាងនេះ

យោងតាមទំព័រទី 29 នៃ *សៀវភៅណែនាំ* ក្នុងនាមជាអ្នកសម្ភាស អ្នកគួរតែជំនួស “[ថ្ងៃបច្ចុប្បន្ននៃសប្ដាហ៍]” ជាមួយនឹងឈ្មោះថ្ងៃនៃសប្ដាហ៍ ជាពេលដែលការសម្ភាសធ្វើឡើង។ ឧទាហរណ៍ ៖ ប្រសិនបើការសម្ភាសធ្វើឡើងនៅថ្ងៃអង្គារ នោះចូរអានសំណួរថា ៖ “តើមានប៉ុន្មានថ្ងៃដែរកាលពី ៧ ថ្ងៃកន្លងមកនេះ (ពោលគឺ តាំងពីថ្ងៃអង្គារមុនរហូតដល់ថ្ងៃម្សិលមិញ) ដែលគ្រួសារនេះបានពិសាផ្លែចេក ផ្លែប៉ោម ផ្លែក្រូច ឬផ្លែក្រូចឃ្វិច?

*កូនសៀវភៅណែនាំ* មិនបានផ្ដល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

**១០. កាលពី ៧ ថ្ងៃកន្លងមកនេះ (ពោលគឺតាំងពី ថ្ងៃបច្ចុប្បន្ននៃសប្ដាហ៍ មុនរហូតដល់ម្សិលមិញ) តើគ្រួសារនេះមានបរិភោគផលិតផលធ្វើពីទឹកដោះគោ (ទឹកដោះគោស្រស់ ទឹកដោះគោខាប់ ឬម្សៅទឹកដោះគោ ការ៉េមគី ឈីស ឬផលិតផលធ្វើពីទឹកដោះគោផ្សេងទៀត) ដែរឬទេ?**

ក. មិនមានទេ

ខ. មាន

យោងតាមទំព័រទី 29 នៃសៀវភៅណែនាំ ក្នុងនាមជាអ្នកសម្ភាស អ្នកគួរតែជំនួស "[ថ្ងៃបច្ចុប្បន្ននៃសប្ដាហ៍]" ជាមួយនឹងឈ្មោះថ្ងៃនៃសប្ដាហ៍ ជាពេលដែលការសម្ភាសធ្វើឡើង។ ឧទាហរណ៍ ៖ ប្រសិនបើការសម្ភាសធ្វើឡើងនៅថ្ងៃអង្គារ នោះចូរអានសំណួរថា ៖ កាលពី ៧ ថ្ងៃកន្លងមកនេះ (ពោលគឺ តាំងពីថ្ងៃអង្គារមុនរហូតដល់ថ្ងៃម្សិលមិញ) តើគ្រួសារនេះមានបរិភោគផលិតផលធ្វើពីទឹកដោះគោ (ទឹកដោះគោស្រស់ ទឹកដោះគោខាប់ ឬម្សៅទឹកដោះគោ ការ៉េមគីឈីស ឬផលិតផលធ្វើពីទឹកដោះគោផ្សេងទៀត) ដែរឬទេ?

*កូនសៀវភៅណែនាំ* មិនបានផ្ដល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។